អ៊ិនធើណេសិនណល ស្គូល អហ្វ សៀមរាប
International School of Siem Reap

សេចក្តីជូនដំណឹងពីសាលា
បឋមសិក្សាសម្រាប់ខែសីហា
ឆ្នាំ២០១៨
វុលៈ៣
បោះផ្សាយលើកទី១

# ព័ត៌មានពីសាលាបឋមសិក្សាសម្រាប់ខែសីហា ឆ្នាំ២០១៨

## សូមគោរព និងស្វាគមន៍ការមកកាន់សាលាអន្តរជាតិយើងខ្ញុំ



ស្វាគមន៍សម្រាប់ឆ្នាំសិក្សាថ្មីនៅសាលាអន្តរជាតិ ISSR ជាមួយអាគារសិក្សាថ្មីដ៏ធំ។ គិតត្រឹមមួយរយៈខ្លីប៉ុណ្ណោះដែលលោក-លោកស្រីក៏ដូចជាលោកគ្រូអ្នកគ្រូ បានស្គាល់ថ្នាក់រៀន ព្រមទាំងតំបន់មួយចំនួនក្នុងបរិវេណសាលា ចំពោះលោកគ្រូ អ្នកគ្រូក៏បានរៀបចំថ្នាក់រៀនបានរួចរាល់ជាស្រេច។ ទោះជាយ៉ាងណា ការសាងសង់គឺនៅតែបន្តជាបណ្តើរៗ ដូចជាដំបូលអាងហែលទឹកគឺនៅបន្ត ហើយអាចនឹងរួចរាល់ក្នុងខែកញ្ញានេះ។ ដូច្នេះហើយសិស្សទាំងអស់គឺត្រូវបន្តរម៉ោងអប់រំកាយរបស់ពួកគេជាបន្តរទៀត។ លោក-លោកស្រីប្រហែលជាទទួលបានព័ត៌មានអំពីកម្មវិធីសិក្សា កាលវិភាគសិក្សា និងព័ត៌មានអំពីលោកគ្រូ អ្នកគ្របន្ទុកថ្នាក់ រួចរាល់ហើយ។ ក្នុងនោះបានរៀបរាប់អំពីព័ត៌មានចាំបាច់សម្រាប់ការសិក្សារបស់កូនៗលោក-លោកស្រី។ ប្រសិនបើលោក-លោកស្រីពុំទាន់ទទួលបានព័ត៌មានទាំងនេះសូមធ្វើការសាកសួរផ្នែករដ្ឋបាលដើម្បីទទួលយកឯកសារ។ នាងខ្ញុំក៏សូមស្វាគមន៍ដល់លោកគ្រូអ្នកគ្រូថ្មី បុគ្គលិកទាំងអស់ក្នុងកិច្ចសហការល្អទាំងអស់គ្នា ហើយក៏សង្ឃឹមថាគ្រប់ៗគ្នា នឹងមានភាពរីករាយ ស្នាមញញឹមក្នុងសាលា ក៏ដូចជាបន្តផ្តល់ព័ត៌មាន សហការល្អជាមួយលោក-លោកស្រីលើកិច្ចការអប់រំជាបន្តបន្ទាប់។

## ការជូនកូនៗមកសាលារៀន

សាលាមានទីតាំងទទួលកូនៗលោក-លោកស្រីធំទូលាយជាងមុន ដើម្បីឲ្យពួកគេអាចចុះដើរចូលសាលាដោយសុវត្ថិភាព។ សូមលោក-លោកស្រីមេត្តាដាក់កូនៗចុះ ដោយបើករថយន្តទៅផ្នែកខាងចុងឲ្យបានឆ្ងាយដើម្បីមាតាបិតាដែលបើកពីក្រោយអាចដាក់កូនៗចុះជាបន្តបន្ទាប់ ដើម្បីងាយស្រួលចរាចរហើយកូនៗអាចដើរចូលសាលាបានលឿន។ កាលណារថយន្តលោក-លោកស្រីមានការឈប់ ឬចតដែលមិនមានជាទីតាំងចុះនឹងបង្កឲ្យមានការយឺតយ៉ាវដល់អ្នកបើកបរពីក្រោយ ដូចនេះសូមមេត្តាបន្តបើករថយន្តទៅមុខជាបណ្តើរៗ។ ក្រុមអ្នកគ្រូជំនួយការគ្របង្រៀន ព្រមទាំងសន្តិសុខ នឹងមិនបើកទ្វាឡានទេលុះត្រាតែរថយន្តបានបើកមកខាងមុខឲ្យ បានឆ្ងាយគួរសមសិន។ ការចូលរួមសហការពីសំណាក់លោក-លោកស្រី នឹងជួយឲ្យចរន្តនៃការចុះចតបានលឿនជាងមុន។ សម្រាប់ម៉ូតូ កង់ លោក-លោកស្រីអាចចតនៅផ្នែកខាងស្តាំពេលចូលមកសាលា ឬអាចបន្តមកចតនៅផ្នែកខាងឆ្វេង ទល់មុខទីតាំងទទួលសិស្ស។

## អំពីកម្មវិធី Class Dojo



កម្មវិធី Class Dojo សាលានឹងបន្តប្រើដើម្បីធ្វើការទំនាក់ទំនងមកកាន់មាតាបិតាឬអាណាព្យាបាលសិស្សបន្តទៅទៀត។ កាលពីឆ្នាំមុន សាលាទទួលបានការគាំទ្រវិជ្ជមានពីសំណាក់លោក-លោកស្រីដោយសារពួកគាត់ទទួលបានរូបភាព សកម្មភាពថ្មីៗក្នុងថ្នាក់រៀនរបស់សិស្ស ព្រមទាំងអាចសរសេរសារតាមដានការសិក្សារបស់កូនៗនៅក្នុងកម្មវិធី Class Dojo នេះផងដែរ។ កម្មវិធី Class Dojo គឺជាមធ្យោបាយដ៏ល្អក្នុងការទំនាក់ទំនងរវាងអាណាព្យាបាល និងព័ត៌មានពីសាលា។ ប្រសិនបើលោក-លោកស្រីបានបង្កើតម្តងហើយកាលពីឆ្នាំមុន គឺពុំចាំបាច់បង្កើតម្តងទៀតទេ។ កាលណាសិស្សដែលបញ្ចូលក្នុងថ្នាក់ថ្មី អាស័យដ្ឋានអ៊ីម៉ែលរបស់លោក-លោកស្រីពីមុន នឹងបញ្ជូនសារភ្ជាប់មកថ្នាក់រៀនថ្មីនោះ។ ប្រសិនបើលោក-លោកស្រីពុំបានចុះឈ្មោះនៅឡើយ លោកគ្រូអ្នកគ្រូ នឹងផ្ញើលិខិតមួយច្បាប់ដើម្បីផ្តល់ព័ត៌មានជូនក្នុងការចុះឈ្មោះបង្កើតកម្មវិធីនេះ។

## អំពីអាហារថ្ងៃត្រង់

ទីធ្លាសម្រាប់ញ៉ាំអាហារថ្ងៃត្រង់ធំទូលាយ មានខ្យល់អាកាសចេញចូល ដែលសិស្សទាំងអស់រីករាយក្នុងម៉ោងពិសាអាហារថ្ងៃត្រង់របស់ពួកគេ។ នាងខ្ញុំក៏សូមថ្លែងអំណរគុណដល់លោក-លោកស្រីដែលជាមាតាបិតា និងអាណាព្យាបាលសិស្សថ្នាក់ Reception 2 ដែលបានចូលរួមជួយសម្រួលដល់កូនៗក្នុងម៉ោងអាហារថ្ងៃត្រង់នេះ។ សាលានឹងបន្តអនុញ្ញាតលោក-លោកស្រីត្រឹមថ្ងៃទី៣១ ខែសីហានេះប៉ុណ្ណោះ។ ចាប់ពីថ្ងៃទី៣ ខែកញ្ញា សាលានឹងទទួលខុសត្រូវក្នុងការសម្របសម្រួលសិស្សញ៉ាំអាហារថ្ងៃត្រង់ដោយខ្លួនឯង ដូច្នោះលោក-លោកស្រីពុំបានអនុញ្ញាតឲ្យចូលក្នុងកន្លែងញ៉ាំបាយទៀតឡើយ។ នាងខ្ញុំសូមថ្លែងអំណរគុណដល់លោក-លោកស្រីដែលបានជួយសម្របសម្រួលដល់កូនៗញ៉ាំអាហារថ្ងៃត្រង់ក្នុងរយៈពេលកន្លងមកនេះ។

សាអន្តរជាតិ ISSR តម្រូវឲ្យសិស្សានុសិស្សទាំងអស់ញ៉ាំអាហារសម្រន់ណាដែលមានផាសុកភាពប៉ុណ្ណោះ។ សូមលោក-លោកស្រីផ្តល់ជូនអាហារសម្រន់ណាដែលមានផាសុកភាពដល់កូនៗ ពេលមកសាលារៀន។




*We are one,*
*But we are many.*

## អំពីការណាត់ជួបមាតាបិតា ឬអាណាព្យាបាលសិស្ស

ការណាត់ជួបមាតាបិតា ឬអាណាព្យាបាលសិស្សនឹងប្រព្រឹត្តទៅនៅថ្ងៃសុក្រ ទី៧ ខែកញ្ញា ឆ្នាំ២០១៨ វេលាម៉ោង ៥:០០ល្ងាច។ សូមលោក-លោកស្រីមេត្តាអញ្ជើញចូលរួមឲ្យបានគ្រប់ៗគ្នា ពីព្រោះការជួបជុំនេះគឺមានសារៈសំខាន់ណាស់ ដើម្បីបានជួបផ្ទាល់ជាមួយលោកគ្រូ អ្នកគ្រូបន្ទុកថ្នាក់ ក៏ដូចជាបានឃើញថ្នាក់រៀនរបស់កូនៗលោក-លោកស្រី។ បន្ទាប់ពីការអញ្ជើញជួបជាមួយលោកគ្រូ អ្នកគ្រូ និងពិនិត្យថ្នាក់រៀនរួចរាល់ហើយ លោក-លោកស្រីអាចអញ្ជើញពិសារអាហារសម្រន់ និងភេសជ្ជៈ ដែលសាលាផ្តល់ជូន។ ដូចបានជម្រាបជូនលោក-លោកស្រីខាងលើ សូមលោក-លោកស្រីអញ្ជើញចូលរួមនៅសាលាអន្តរជាតិ ISSR បឋមសិក្សាទាំងអស់គ្នា ដើម្បីជាឱកាសល្អក្នុងការជួបជាមួយជុំលោកគ្រូ អ្នកគ្រូ របស់កូនៗ រៀងៗខ្លួន។

យើងខ្ញុំទន្ទឹងរង់ចាំការចូលរួម និងស្វាគមន៍លោក-លោកស្រីនៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៨ ខាងមុខ។ ***បញ្ជាក់៖ ការជួបប្រជុំនេះ សម្រាប់តែមាតាបិតា ឬអាណាព្យាបាលតែប៉ុណ្ណោះ។***

## អំពីការចូលរៀនបន្ថែមម៉ោង (After-School Clubs)

ព័ត៌មានអំពីការសិក្សាបន្ថែមម៉ោងសម្រាប់សិស្សថ្នាក់ទី១ ដល់សិស្សថ្នាក់ទី៦នឹងត្រូវបានសរសេរព័ត៌មានបន្ថែមរួចផ្ញើរជូនលោក-លោកស្រីសម្រាប់វគ្គសិក្សាឆ្នាំនេះ។ ការសិក្សាបន្ថែមម៉ោងគឺមានការកំណត់ចំនួនសិស្ស ពិសេសសិស្សានុសិស្សជាច្រើនមានចំណាប់អារម្មណ៍ក្នុងការសិក្សាបន្ថែមម៉ោង (Club) ដូចនេះ សូមលោក-លោកស្រីធ្វើការចុះឈ្មោះកូនៗឲ្យបានឆាប់ដើម្បីជៀសវាងការអាក់ខានមិនបានចូលរៀន។ សូមលោក-លោកស្រីជ្រាបថាសិស្សដែលចុះឈ្មោះមុន នឹងទទួលបានកន្លែងសិក្សាមុន។ ថ្នាក់បន្ថែមម៉ោងនឹងចាប់ផ្តើមពីថ្ងៃចន្ទ ទី៣ ខែកញ្ញា។



## អំពីការយឺតយ៉ាវមកសាលារៀន

ចាប់ពីថ្ងៃចន្ទ ទី៣ ខែកញ្ញាសាលានឹងរៀបចំសៀវភៅកំណត់ត្រា ការមកសាលាយឺតយ៉ាវ (ក្រោយម៉ោង៨:០០ព្រឹក)។ សៀវភៅកំណត់ត្រានឹងដំកល់ទុកកន្លែងទទួលសិស្សនៅច្រកទ្វារខាងមុខដើម្បីឲ្យលោក-លោកស្រីអាចសរសេរអំពីមូលហេតុដែលកូនៗមកសាលាមិនបានទាន់ពេលវេលា។ ការមករៀនយឺតនឹងបង្កការរំខានដល់សិស្សដែលកំពុងសិក្សា នឹងមេរៀនដែលលោកគ្រូ-អ្នកគ្រូកំពុងបង្រៀន ពិសេសវាជាគោលការក្នុងថ្នាក់រៀនដែលមិនចង់ឲ្យមានការយឺតយ៉ាវក្នុងការសិក្សា។ ដូចបានរៀបរាប់អំពីការមកយឺត សូមលោក-លោកស្រីមេត្តាជួយសហការដើម្បីបង្កភាពងាយស្រួលដល់ថ្នាក់រៀនរបស់កូនៗលោក-លោកស្រី ដូច្នោះសូមនាំកូនៗមកសាលាឲ្យបានទាន់ពេលវេលា ឬឲ្យបានមុនកណ្តឹងសាលារោទិ៍។

## អំពីការនាំយកថ្នាំពេទ្យឲ្យកូនៗញ៉ាំ

អំពីការផ្តល់ថ្នាំពេទ្យដល់កូនៗលោក-លោកស្រី។ យើងខ្ញុំដឹងថាពេលខ្លះកូនៗលោក-លោកស្រីត្រូវការថ្នាំពេទ្យ ប៉ុន្តែពួកគាត់ក៏អាចនៅបន្តការសិក្សាផងដែរ។ ចំពោះការផ្តល់ថ្នាំពេទ្យដល់កូនៗលោក-លោកស្រី សូមអញ្ជើញយកមកផ្ញើទុកតាមរយៈការិយាល័យរដ្ឋបាលសាលា។ ខាងផ្នែករដ្ឋបាលនឹងធ្វើការទំនាក់ទំនងលោកគ្រូអ្នកគ្រូដើម្បីផ្តល់ព័ត៌មានបន្ត។ ដូច នេះសូមមាតាបិតាឬអាណាព្យាបាលទាំងអស់ប្រាប់អំពីម៉ោង ឬពេលវេលាដែលកូនៗត្រូវទទួលទានថ្នាំពេទ្យផង។ *ចំណាំ៖* ការផ្តល់ថ្នាំពេទ្យដល់កូនៗលោក- លោកស្រីគឺត្រូវមានការអនុញ្ញាតិពីសំណាក់លោក-លោកស្រីជាមុនសិន។ ការផ្តល់ថ្នាំសង្កូវ ឬទទួលថ្នាំ សង្កូវពីសំណាក់លោក-លោកស្រីគឺតែងមានការកត់ត្រាត្រឹមត្រូវក្នុងបញ្ជីកំណត់ត្រានៅផ្នែករដ្ឋបាល ដើម្បីជាឯកសារដំកល់ទុក។

**ដបទឹក**

សិស្សទាំងអស់ចាំបាច់ត្រូវមានដបទឹកផ្ទាល់ខ្លួនមួយដែលមានគុណភាពល្អសម្រាប់យកមកសាលា។ ដបទឹកប្រភេទកែវគឺមិនត្រូវបានអនុញ្ញាតិឲ្យយកមកសាលាទេ។ សូមលោក-លោកស្រីពិនិត្យ និងជួយផ្តល់ដបទឹកដែលមានសុវត្ថិភាពដល់កូនៗពេលមកសាលា



សិស្សថ្នាក់ទី1B កំពុងតែធ្វើការក្នុងថ្នាក់ជាគូរដើម្បីរៀបតាមមេរៀន "ប្រមាញ់ សត្វខ្លាឃ្មុំ"។



សិស្សឈ្មោះជីងជីង និងសិស្សឈ្មោះមិញ កំពុងតែអានសៀវភៅក្នុងថ្នាក់ ដែលជាកម្មវិធីសាលាឈ្មោះ "កម្មវិធីជ្រុងមួយនៃការអាន"។




**កម្មវិធី** Star of the Month

សូមលោក-លោកស្រីអញ្ជើញ ចូលរួមនៅពេលព្រឹកវេលាម៉ោង៨:00 នាទី៖

- ថ្ងៃ**អង្គារ៍** ទី០៤ ខែ**កញ្ញា** ថ្នាក់ Nursery ដល់ថ្នាក់ ទី1 (ថ្នាក់ Reception2B ធ្វើការសម្តែង)
- ថ្ងៃ**ពុធ** ទី**០៥** ខែ**កញ្ញា** ថ្នាក់ទី២ ដល់ថ្នាក់ទី៦ (ថ្នាក់ទី 6A ធ្វើការសម្តែង )

សិស្សទាំងអស់កំពុងតែអនុវត្តន៍ការសម្តែងរបស់ពួកគេប្រកបដោយក្តីរីករាយដើម្បីសម្តែងជូនលោក-លោកស្រីកម្សាន្ត។

កម្មវិធីមើលថែក្មេងពេលរសៀលសម្រាប់ថ្នាក់ Reception1 និងថ្នាក់ Nursery បានចាប់ដំណើរការហើយ។ ប្រសិនបើលោកអ្នកមានចំ ណាប់អារម្មណ៍សូមអញ្ជើញមកសាកសួរព័ត៌មាននៅការិយាល័យរដ្ឋបាលសាលា។